ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ធំ
-សំណុំរឿងព្រហ្មទណ្ឌលេខ: ៨៦៩
ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៧
-សំណុំរឿងជំនុំជម្រះលេខ: ៧២៣
ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៧
-សាលក្រមព្រហ្មទណ្ឌលេខ: ២៦(ខ)
ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកំពង់ធំ

-កាលបរិច្ឆេទបើកសវនាការជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ។
-កាលបរិច្ឆេទប្រកាសសាលក្រមជាសាធារណៈនៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ។

**ដោយសមាសភាពចូលរួម ៖**

**ចៅក្រមជំនុំជម្រះ**

-លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
-លោក [redacted] ជាចៅក្រមក្រុមប្រឹក្សាជំនុំជម្រះ
-លោក [redacted] ជាចៅក្រមក្រុមប្រឹក្សាជំនុំជម្រះ

**តំណាងអយ្យការ**

-លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកំពង់ធំ

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកំពង់ធំ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ: ៨៦៩ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៧ ដែលមាន៖

**ជនជាប់ចោទ៖**

១/.ឈ្មោះ [redacted] **ខែសា ហៅ សាល** ភេទប្រុស អាយុ ១៧ឆ្នាំ ជាតិខ្មែរ កើត [redacted] ក្រយា ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ សាសនាព្រះពុទ្ធ នៅលីវ ឪពុកឈ្មោះ [redacted] "រស់" ម្តាយឈ្មោះ [redacted] "រស់" ទោសពីមុនគ្មាន ។ "ឃុំខ្លួន"

**-ឃុំខ្លួនបណ្តោះអាសន្ន៖** នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៨ តាមដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្នលេខ: ៣៨៣/១៧ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៧ ។

២/.ឈ្មោះ [redacted] **ផានី** ភេទប្រុស អាយុ ១៨ឆ្នាំ ជាតិខ្មែរ កើត និងរស់នៅភូមិក្រយាត្បូង [redacted] ប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ សាសនាព្រះពុទ្ធ នៅលីវ ឪពុកឈ្មោះ [redacted] "រស់" ម្តាយឈ្មោះ [redacted] "រស់" ទោសពីមុនគ្មាន ។ "ឃុំខ្លួន"

**-ឃុំខ្លួនបណ្តោះអាសន្ន៖** នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៨ តាមដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្នលេខ: ៣៨៤/១៧ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៧ ។



CamScanner

ឈ្មោះ ០៣នាក់ទៀត នៅក្រោមផ្ទះរបស់ឈ្មោះ ដា ឃើញដូច្នេះ ពួកខ្លួនក៏បានចូលទៅទាំងអស់គ្នាទៅមើលមុខពួកវាធ្លាប់វាយពួកខ្លួនពីមុនឬអត់? ពេលទៅមើលឃើញស្គាល់ក៏បាននាំគ្នាចេញមកវិញ ជិះម៉ូតូចេញពីផ្ទះឈ្មោះដា ទៅដល់ភូមិក្រយាត្បូង ក៏បាននៅចាំពួនស្ទាក់ចាំវាយពួកវាដើម្បីសងសឹកពួកខ្លួនទុកម៉ូតូចោល រួចនាំគ្នាកាន់ដំបង០១ម្នាក់នៅដៃចាំផ្លូវវាយ ចាំបានប្រហែលជាកន្លះម៉ោង ទើបពួកវាបានជិះម៉ូតូ ០២គ្រឿង មានគ្នា ០៤នាក់ មកដល់ងងឹតមើលមិនឃើញទេ ស្រាប់តែឈ្មោះ [redacted] ទាង បានវាយទៅលើអ្នកជិះម៉ូតូ ០១ដំបងមិនដឹងថាឈ្មោះអ្វីនោះទេ ធ្វើឱ្យម៉ូតូដួលធ្លាក់ទៅលើស្នាមភ្លោះ ហើយមិនដឹងត្រូវរបួសត្រង់ណានោះទេ។ ពេលនោះខ្លួនមិនបានវាយទៅលើអ្នកជិះម៉ូតូនោះទេ គ្រាន់តែបានកាន់ដំបងចាំមើលតែប៉ុណ្ណោះ ហើយពេលដែលឈ្មោះ [redacted] ទាង វាយអ្នកជិះម៉ូតូរួច ខ្លួនមានការភិតភ័យក៏បានទម្លាក់ដំបងចោលរត់ទៅយកម៉ូតូ និងបានឌុបឈ្មោះ ទាង និងឈ្មោះ ផានី ត្រឡប់មកផ្ទះវិញ នៅផ្ទះបងជាមួយឈ្មោះ ផានី។ ចំណែកឈ្មោះ [redacted] ទាង បានទៅដេកផ្ទះរបស់វាទៅ ។ លុះព្រឹកឡើងសមត្ថកិច្ចបានមកឃាត់រូបខ្លួននាំទៅសាកសួរនៅប៉ុស្តិ៍ និងបញ្ជូនរូបខ្លួនមកកាន់តុលាការ ចំណែកឯឈ្មោះ [redacted]ទាង បានរត់គេចខ្លួនបាត់ហើយ ។ ខ្លួនធ្លាប់ត្រូវបានបក្ខពួករងគ្រោះវាយខ្លួន និងមិត្តភក្តិម្តង កាលពីពេលដែលលេងបុណ្យភូមិសុជុស ទើបបណ្តាលឲ្យខ្លួនមានគំនុំចង់វាយវិញ តែមិនមែនខ្លួនទេ គឺឈ្មោះ[redacted]ទាង ទេជាអ្នកវាយផ្ទាល់ ។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted]ផានី នាពេលសវនាការបានឆ្លើយថា: កាលពីថ្ងៃទី២៤ ខែធ្នូ ឆ្នាំ ២០១៧ វេលាម៉ោង២០និង៣០នាទីយប់ ពេលនោះខ្លួនបានឡើងជិះម៉ូតូមានគ្នាបីនាក់ មានរូបខ្លួន, ឈ្មោះ សាល និងឈ្មោះ [redacted] ទាង មកពីផឹកទឹកត្នោតជូរនៅភូមិច្រឹងមកភូមិក្រយា ក៏បានជួបឈ្មោះ ដា និងបក្សពួកមិនស្គាល់ឈ្មោះ ០៣នាក់ទៀត នៅក្រោមផ្ទះឈ្មោះ ដា ឃើញដូច្នេះ ពួកខ្លួនក៏បានចូលទៅទាំងអស់គ្នាទៅមើលមុខពួកវាថាពួកវាធ្លាប់វាយពួកខ្លួនពីមុន ឬអត់ ពេលទៅមើលឃើញស្គាល់ក៏បាននាំគ្នាចេញមកវិញ ជិះម៉ូតូចេញពីផ្ទះឈ្មោះ ដា ទៅដល់ភូមិក្រយាត្បូង ក៏បាននៅចាំពួនស្ទាក់ចាំវាយពួកវាដើម្បីសងសឹក ហើយបានទុកម៉ូតូចោល រួចនាំគ្នាកាន់ដំបង ០១ម្នាក់នៅដៃចាំស្ទាក់វាយ ចាំបានប្រហែលជាកន្លះម៉ោង ទើបពួកវាបានជិះម៉ូតូ ០២គ្រឿង មានគ្នា ០៤នាក់ មកដល់ងងឹតមើលមិនឃើញទេ ស្រាប់តែឈ្មោះ [redacted] ទាង បានវាយទៅលើអ្នកជិះម៉ូតូ ០១ដំបង មិនដឹងថាឈ្មោះអ្វីនោះទេ ធ្វើឱ្យម៉ូតូដួលធ្លាក់ទៅលើស្នាមភ្លោះ ហើយមិនដឹងត្រូវរបួសត្រង់ណានោះទេ។ ពេលនោះខ្លួនមិនបានវាយទៅលើអ្នកជិះម៉ូតូនោះទេ គ្រាន់តែបានកាន់ដំបងចាំមើលតែប៉ុណ្ណោះ ហើយពេលដែលឈ្មោះ [redacted] ទាង វាយអ្នកជិះម៉ូតូរួច ខ្លួនមានការភិតភ័យក៏បានទម្លាក់ដំបងចោលរត់ទៅយកម៉ូតូជិះត្រលប់មកផ្ទះវិញនៅផ្ទះជាមួយឈ្មោះ សាល ចំណែកឈ្មោះ [redacted] ទាង បានទៅដេកផ្ទះរបស់វាទៅ ។ លុះព្រឹកឡើងសមត្ថកិច្ចបានចុះមកឃាត់ខ្លួនទៅសាកសួរនៅប៉ុស្តិ៍រួចបញ្ជូនមកតុលាការតែម្តង ចំណែកជនដៃដល់ឈ្មោះ [redacted] ទាង បានរត់គេចខ្លួនបាត់ហើយ ។ ខ្លួនសូមបញ្ជាក់ថា ខ្លួនធ្លាប់បានបក្ខពួកជនរងគ្រោះស្ទាក់វាយខ្លួន និងពួកម៉ាកម្តង កាលពីពេលដែលលេងបុណ្យភូមិសុជុសតែមិនបានវាយត្រូវខ្លួនទេ គឺត្រូវពួកម៉ាកខ្លួនឈ្មោះ សាល ទើបបណ្តាលឱ្យខ្លួន និងបក្ខពួកមានគំនុំចង់វាយសងសឹកវិញ តែមិនមានបំណងវាយឱ្យស្លាប់នោះទេ គ្រាន់តែបម្រុងតែប៉ុណ្ណោះ។ តែអ្នកដែលវាយជនរងគ្រោះនោះមិនមែនខ្លួននោះទេ គឺឈ្មោះ [redacted] ទាង ទេជាអ្នកវាយផ្ទាល់ ។ ខ្លួនសូមសំណូមពរឱ្យតុលាការលើកលែងចោទប្រកាន់ និងដោះលែងខ្លួនឱ្យមានសេរីភាពវិញផង ព្រោះខ្លួនមិនមែនជាអ្នកវាយផ្ទាល់នោះទេ គ្រាន់តែទៅជាមួយតែប៉ុណ្ណោះ ។

-ក្រឡាបញ្ជីសវនាការអានអំណានចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឈេម នៅដំណាក់ការស៊ើបសួរ៖ មុនពេលកើតហេតុខ្លួននៅចំការព្រៃតំបន់ទប់រទេះ ជាមួយកូនប្រុសឈ្មោះ [redacted] សាយ ហើយពេលដែលគោយន្តបែកកង់ ខ្លួនបានប្រើវាឱ្យយកគោយន្តទៅប៉ះនៅក្នុងភូមិ រួចវាបានប្រើបងវាឈ្មោះ [redacted] សំ ឱ្យមកចំការវិញ ហើយវាប្រាប់ថា វានៅធ្វើកូនកំដរការនៅភូមិអន្លង់ជោ។ នៅវេលាម៉ោង ៨យប់ ស្រាប់តែគេទូរស័ព្ទប្រាប់ថា កូនរបស់ខ្លួនឈ្មោះ [redacted] សាយ គេវាយរបួសធ្ងន់គេយកទៅដាក់នៅផ្ទះពេទ្យឈ្នួលឈ្មោះ អេង ។ ពេលនោះនាងខ្ញុំរៀបចំធ្វើបុណ្យតាមប្រពៃណីឱ្យកូន ហើយសមត្ថកិច្ចបានទៅសាកសួរខ្លួន។ ខ្លួនបានដឹងតាមការដែលគេនិយាយប្រាប់ថា ឈ្មោះ សាល និងឈ្មោះម្នាក់ទៀតមិនស្គាល់ទេ រស់នៅភូមិក្រយា ជាអ្នកវាយកូននាងខ្ញុំបណ្ដាលឱ្យស្លាប់ ដោយសារយកដំបងបុកចំពោះ និងវាយចំដៃជាច្រើនកន្លែង ។ ខ្លួនសំណូមពរមកតុលាការថា ជួយផ្ដន្ទាទោសលើជនជាប់ចោទតាមច្បាប់ និងសុំទាមទារសំណងជម្ងឺចិត្តចំនួន ១៥.០០០(មួយម៉ឺនប្រាំពាន់)ដុល្លារអាមេរិក។

-ក្រឡាបញ្ជីសវនាការអានអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] សោ នៅដំណាក់កាលស៊ើបសួរ៖ នៅពេលកើតហេតុឈ្មោះ សាយ បានមកផ្ទះខ្លួន បានបបួលខ្លួនទៅផឹកនៅផ្ទះបងថ្លៃ ពេលនោះខ្លួនក៏បាននាំគ្នាផឹកទឹកត្នោតជូរនៅផ្ទះបងថ្លៃឈ្មោះ សាង នៅភូមិអន្លង់ជូរ ពេលផឹកទឹកត្នោតជូរអស់ប្រហែលជា ០៥លីត្រ រួចនាំគ្នាជិះម៉ូតូពីរគ្រឿងមានគ្នា ០៣នាក់ មានរូបខ្លួន, ឈ្មោះ [redacted] ហុង និងឈ្មោះ [redacted] សាយ នាំទៅលេងផ្ទះឈ្មោះ ដា នៅភូមិក្រយា រួចពួកខ្លួនបាននាំគ្នាជិះត្រលប់មកវិញដោយបានជិះម៉ូតូពីរគ្រឿង ពេលនោះខ្លួនបានជិះជាមួយឈ្មោះ សាយ ជាអ្នកឌុបខ្លួន, ឈ្មោះ ហុង ឌុបឈ្មោះ ដា ទៅផ្ទះវិញ ពេលដែលពួកខ្លួនជិះមកដល់កែងមានព្រៃ នៅវេលាម៉ោង ៨ យប់ជាង ស្រាប់តែមានមនុស្សប្រហែលជា០៤ ទៅ០៥នាក់ បាននាំគ្នាពួនក្នុងព្រៃដោយមានអ្នកខ្លះកាន់ដំបង និងអ្នកខ្លះកាន់ដុំថ្ម បាននាំគ្នាគប់ និងយកដំបងវាយមកលើរូបខ្លួនត្រូវចំក្បាលធ្វើឱ្យបែកឈាម ចំណែកឈ្មោះ សាយ ត្រូវពួកវាវាយ ០១ដំបងចំទ្រូង បណ្ដាលឱ្យដួល ទើបពួកខ្លួនបានរត់ចោលម៉ូតូ បានបន្តិចស្រាប់តែឈ្មោះ សាយ ស្រែកថា ជួយផង វាឈឺទ្រូងប្រកាច់ដេកនៅផ្លូវ ហើយខ្លួនបាននាំមកផ្ទះពេទ្យប្រហែលជាមួយម៉ោង ទើបឈ្មោះ សាយ បានស្លាប់បាត់ទៅ។ ចំពោះអ្នកដែលវាយពួកខ្លួន និងជនរងគ្រោះ បណ្ដាលឱ្យស្លាប់នោះខ្លួនបានស្គាល់ម្នាក់ឈ្មោះ ផានី និងអ្នកផ្សេងទៀត មិនស្គាល់មិនឃើញមុខ មិនស្គាល់ឈ្មោះ។ ហើយខ្លួនក៏មិនធ្លាប់មានទំនាស់អ្វី ជាមួយពួកវានោះទេ ហើយក៏មិនដឹងមូលហេតុអ្វីបានជាពួកវាស្ទាក់វាយខ្លួនដែរ។

-ក្រឡាបញ្ជីសវនាការអានអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] ហុង នៅដំណាក់កាលស៊ើបសួរ៖ នៅថ្ងៃកើតហេតុឈ្មោះ សាយ បានមកផ្ទះខ្លួន ហើយបបួលខ្លួនទៅផឹកនៅផ្ទះបងថ្លៃ ពេលនោះខ្លួនបាននាំគ្នាផឹកទឹកត្នោតជូរនៅផ្ទះបងថ្លៃឈ្មោះ សាង នៅភូមិអន្លង់ជូរ ពេលផឹកទឹកត្នោតជូរអស់ប្រហែលជា ០៥លីត្រ រួចនាំគ្នាជិះម៉ូតូពីរគ្រឿងមានគ្នា ០៣នាក់ មានរូបខ្លួន, ឈ្មោះ [redacted] សោ ,ឈ្មោះ [redacted] សាយ នាំគ្នាទៅលេងផ្ទះឈ្មោះ ដា នៅភូមិក្រយា រួចពួកខ្លួនក៏បាននាំគ្នាជិះត្រលប់មកវិញដោយបានជិះម៉ូតូពីរគ្រឿង ពេលនោះខ្លួនបានជិះឌុបឈ្មោះ ដា, ឈ្មោះ សាយ ឌុបឈ្មោះ សោ ទៅផ្ទះវិញ ពេលដែលពួកខ្លួនបានជិះមកដល់ផ្លូវកែងមានព្រៃ នៅវេលាម៉ោង៨យប់ជាង ស្រាប់តែមានមនុស្សប្រហែលជា ០៤ ទៅ០៥នាក់ បាននាំគ្នាពួនក្នុងព្រៃដោយមានអ្នកខ្លះកាន់ដំបង និងអ្នកខ្លះកាន់ដុំថ្ម បាននាំគ្នាគប់ និងយកដំបងវាយមកលើរូបខ្លួន និងឈ្មោះ ដាតែខ្លួនបានគេចផុត ចំណែកឈ្មោះ សោ ត្រូវចំក្បាលធ្វើឱ្យបែកឈាម និងឈ្មោះ សាយ ត្រូវពួកវាវាយនឹងដំបងចំទ្រូង ០១ដំបង បណ្ដាលឱ្យដួលរត់ចោលម៉ូតូ បានបន្តិច



CamScanner

ស្រាប់តែឈ្មោះ សាយ វាស្រែកថាជួយផង វាឈើទ្រូងប្រកាច់ដេកនៅលើផ្លូវ ហើយពួកខ្លួនក៏បាននាំមកផ្ទះពេទ្យ ប្រហែលជាមួយម៉ោង ទើបឈ្មោះ សាយ បានស្លាប់បាត់ទៅ។ ចំពោះអ្នកដែលវាយខ្លួន និងជនរងគ្រោះបណ្តាលឱ្យស្លាប់នោះខ្លួនស្គាល់ម្នាក់ឈ្មោះ ផានី និងអ្នកផ្សេង ទៀតមិនស្គាល់ មិនឃើញមុខ និងមិនស្គាល់ឈ្មោះ។ ហើយខ្លួនក៏មិនធ្លាប់មានទំនាស់អ្វី ជាមួយពួកវានោះទេ ហើយក៏មិនដឹងមូលហេតុអ្វីបានជាពួកវាស្ទាក់វាយខ្លួនដែរ ។

-ក្រឡាបញ្ជីសវនាការអានអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] ទ៉ាន់ដា បានឆ្លើយបំភ្លឺនៅដំណាក់កាលស៊ើបសួរ៖ ឈ្មោះ [redacted] សោ , ឈ្មោះ [redacted] សាយ និងឈ្មោះ [redacted] ហុង បាននាំគ្នាទៅលេងផ្ទះរបស់ខ្លួន នៅភូមិក្រយា រួចពួកខ្លួនក៏បានជិះត្រលប់មកវិញ ដោយបានជិះម៉ូតូពីរគ្រឿង ពេលនោះខ្លួនឈ្មោះ ហុង ជាអ្នកឌុប, ឈ្មោះ [redacted] ឌុប ឈ្មោះ សោ ទៅភូមិអន្លង់ជួរ ពេលដែលពួកខ្លួនជិះមកដល់ផ្លូវកែងមានព្រៃ នៅវេលាម៉ោង៨យប់ជាង ស្រាប់តែមានមនុស្ស ប្រហែលជា ០៤ ទៅ ០៥នាក់ បាននាំគ្នាពួកក្នុងព្រៃដោយមានអ្នកខ្លះកាន់ដំបង និងអ្នកខ្លះកាន់ដុំថ្ម បាននាំគ្នាយកដំបងវាយមកលើរូបខ្លួន និងឈ្មោះ ហុង តែខ្លួនគេចផុត ចំណែកឈ្មោះ សោ ត្រូវបានពួកវាវាយចំក្បាលធ្វើឱ្យបែកឈាម និងឈ្មោះ សាយត្រូវពួកវាវាយដំបងចំទ្រូង ០១ដំបង បណ្តាលឱ្យដួល រត់ចោលម៉ូតូ បានបន្តិចស្រាប់តែឈ្មោះ សាយ បានប្រាប់ថា វាស្រែកថាជួយផង វាឈើទ្រូងប្រកាច់ដេកនៅផ្លូវ ហើយពួកខ្លួនក៏បាននាំមកផ្ទះពេទ្យ ប្រហែលជាមួយម៉ោងទើបឈ្មោះ សាយ បានស្លាប់បាត់ទៅ។ ចំពោះអ្នកដែលវាយខ្លួន និងជនរងគ្រោះបណ្តាលឱ្យស្លាប់នោះខ្លួនស្គាល់ច្បាស់ឈ្មោះ ផានី,ឈ្មោះ [redacted] ទាង និងឈ្មោះ សាល អ្នករស់នៅភូមិជាមួយខ្លួន និងអ្នកផ្សេងទៀតមិនបានឃើញមុខទេ។ ខ្លួនបានសួរពួកកវាថា ហេតុអ្វីបានវាយមកលើរូបខ្លួន វាប្រាប់ថា ពួកខ្លួនធ្លាប់វាយពួកវា ទើបពួកវាសងសឹក ។

**ឆ្លងតាមការសួរដេញដោលក្នុងសវនាការ៖**

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា៖ តាមការស្តាប់ចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ខែសា ហៅ សាល, ឈ្មោះ [redacted] ផានី រួមទាំងការស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] លេម និងចម្លើយបំភ្លឺរបស់សាក្សីឈ្មោះ [redacted] សោ, សាក្សីឈ្មោះ [redacted] ហុង និងសាក្សីឈ្មោះ [redacted]ាន់ដា រួមទាំងការពិនិត្យភស្តុតាងជាឯកសារទាំងអស់ដែលនៅក្នុងសំណុំរឿង តំណាងអយ្យការយល់ឃើញថា៖ កាលពីថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៧ វេលាម៉ោងប្រហែល២០និង៣០នាទី ពិតជាមានករណី ឃាតកម្មគិតទុកជាមុន ប្រព្រឹត្តដោយឈ្មោះ [redacted] ខែសា ហៅ សាល, ឈ្មោះ [redacted] ផានី និងឈ្មោះ [redacted] ទាង ពិតប្រាកដមែន។ តាមចម្លើយបំភ្លឺរបស់ជនជាប់ចោទ និងចម្លើយរបស់សាក្សីមានភាពស៊ីសង្វាក់ជាមួយនឹងអង្គហេតុនៃករណីឃាតកម្មគិតទុកជាមុនខាងលើ ហេតុដូច្នេះ តំណាងអយ្យការប្តឹងសុំឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ខែសា ហៅ សាល ភេទប្រុស អាយុ ១៧ឆ្នាំ និងឈ្មោះ [redacted] ផានី ភេទប្រុស អាយុ ១៨ឆ្នាំ ពីបទ: "ឃាតកម្មគិតទុកជាមុន" ប្រព្រឹត្តនៅភូមិក្រយាត្បូង ឃុំក្រយា ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ កាលពីថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៧ តាមបញ្ញត្តិមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសន្និដ្ឋាន: កូនក្តីរបស់ខ្លួនបានដឹងខុស ហើយបានស្នើសុំឱ្យតុលាការបន្ធូរបន្ថយទោសផង ហេតុដូចនេះ សូមតុលាការពិចារណាតាមការស្នើសុំ។



CamScanner

-ជនជាប់ចោទឈ្មោះ [redacted] ខែសា ហៅ សាល និងឈ្មោះ [redacted] ផានី សំណូមពរឱ្យតុលាការជួយបន្ធូរបន្ថយទោសឱ្យរូបខ្លួនផង ព្រោះពួកខ្លួនដឹងកំហុសហើយ។

-ក្រោយពីបានដំណើរការកិច្ចពិភាក្សាដេញដោលរួចមក

-ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីស្ដាប់អំណានចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី

-ក្រោយពីស្ដាប់អំណានចម្លើយរបស់សាក្សី

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានធ្វើសេចក្ដីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-ក្រោយពីស្ដាប់សម្ដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់រួចរាល់ហើយ

## សាលាដំបូងខេត្តកំពង់ធំ

## យល់ឃើញថា

១-តុលាការបានទទួលបណ្ដឹងតាមដីកាដំណោះស្រាយលេខ: ៤៣៨ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៨ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ធំ ដែលសម្រេចបញ្ជូនជនត្រូវចោទ៖ ១.ឈ្មោះ [redacted] ខែសា ហៅ សាល ភេទប្រុស អាយុ ១៧ឆ្នាំ ជាតិខ្មែរ ២.ឈ្មោះ [redacted] ផានី ភេទប្រុស អាយុ ១៨ឆ្នាំ ជាតិខ្មែរ និង ៣.ឈ្មោះ [redacted] ទាង ភេទប្រុស អាយុ ២០ឆ្នាំ មកតុលាការដើម្បីជំនុំជម្រះពីបទ៖ "**ឃាតកម្មគិតទុកជាមុន**" ប្រព្រឹត្តនៅភូមិក្រយាត្បូង ឃុំក្រយា ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ កាលពីថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

២-ឆ្លងតាមការសួរដេញដោលក្នុងសវនាការ តាមការស្ដាប់ចម្លើយរបស់ជនជាប់ចោទ តាមការស្ដាប់អំណានចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងសាក្សី និងតាមការពិនិត្យភស្ដុតាងជាឯកសារទាំងអស់នៅក្នុងសំណុំរឿង អាចឱ្យតុលាការជឿជាក់បានថា: កាលពីថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៧ វេលាម៉ោងប្រហែល២០ និង៣០នាទីយប់ ពិតជាមានករណី ឃាតកម្មគិតទុកជាមុន ប្រព្រឹត្តដោយ ១.ឈ្មោះ [redacted] ខែសា ហៅ សាល ភេទប្រុស អាយុ ១៧ឆ្នាំ ២.ឈ្មោះ [redacted] ផានី ភេទប្រុស អាយុ ១៨ឆ្នាំ និង៣.ឈ្មោះ [redacted] ទាង ភេទប្រុស អាយុ ២០ឆ្នាំ ពិតប្រាកដដូចការចោទប្រកាន់របស់តំណាងអយ្យការមែន គប្បីតុលាការសម្រេចផ្ដន្ទាទោសជនជាប់ចោទតាមច្បាប់។

### ភស្ដុតាងដាក់បន្ទុកមាន:

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ខែសា ហៅ សាល និងឈ្មោ[redacted]ានី ដែលបានឆ្លើយបំភ្លឺប្រហាក់ប្រហែលគ្នានាពេលសវនាការថា៖ កាលពីថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៧ ម៉ោង៨និង៣០នាទីយប់ ពេលពួកខ្លួនត្រលប់មកពីផឹកទឹកត្នោតជូរវិញ ក៏បានឃើញឈ្មោះ ដា និងបក្ខពួក០៣នាក់នៅក្រោមផ្ទះ ពួកខ្លួនក៏ចូលទៅមើលមុខ ពេលមើលស្គាល់ ពួកខ្លួនបានជិះម៉ូតូទៅចាំស្ទាក់វាយពួកគេ ដោយពួកខ្លួនកាន់ដំបងមួយម្នាក់ ទៅពួននៅម្ដុំព្រៃត្រង់ចំណុចផ្លូវកែងចាំបានប្រហែលកន្លះម៉ោង ក៏ឃើញពួកវាជិះម៉ូតូ០២គ្រឿងមក ពេលនោះមេឃងងឹតមើលមិនឃើញអ្នកណាជាអ្នកណាទេ ស្រាប់តែឈ្មោះ [redacted] ទាង វាយទៅអ្នកជិះម៉ូតូចំនួន ០១ដំបងបណ្ដាលឱ្យដួលធ្លាក់ស្មាមភ្លោះ ហើយពួកខ្លួនក៏នាំគ្នាជិះម៉ូតូគេចត្រលប់មកផ្ទះវិញ។

-តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] លេម នៅដំណាក់កាលស៊ើបសួរ៖ កាលពីថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៧ ខ្លួននៅចំការឯតំបន់ទប់រទេះ ឯកូនប្រុសរបស់ខ្លួនឈ្មោះ [redacted] សាយ បានទៅកំដរការគេនៅភូមិក្រយា លុះវេលាម៉ោងប្រហែល៨យប់ ស្រាប់តែមានគេទូរស័ព្ទមកប្រាប់ខ្លួនថា កូនប្រុសខ្លួនឈ្មោះ [redacted] សាយ ត្រូវគេវាយរបួសធ្ងន់ លុះពេលខ្លួនត្រលប់មកដល់ផ្ទះកូនប្រុសរបស់ខ្លួនបានស្លាប់បាត់ទៅហើយ ដោយគេប្រាប់ថាឈ្មោះ សាល និងបក្ខពួករស់នៅភូមិក្រយាបានយកដំបងបុកចំពោះ ទើបបណ្តាលឲ្យកូនប្រុសរបស់ខ្លួនស្លាប់។

-តាមចម្លើយបំភ្លឺរបស់សាក្សីឈ្មោះ [redacted] សា, ឈ្មោះ [redacted] ហុង និងឈ្មោះ [redacted] វ៉ាន់ដា បានផ្តល់ចម្លើយប្រហាក់ប្រហែលគ្នានៅដំណាក់ស៊ើបសួរថា៖ ក្រោយពេលពួកខ្លួនចេញពីផឹកស៊ី ក៏បានជិះម៉ូតូត្រឡប់ទៅផ្ទះវិញ ស្រាប់តែមកដល់ចំណុចផ្លូវកែងមានព្រៃ វេលាម៉ោង៨យប់ ស្រាប់តែមានមនុស្សប្រហែលជា០៤ ទៅ០៥នាក់ បាននាំគ្នាពួនក្នុងព្រៃដោយមានខ្លះកាន់ដំបង និងអ្នកខ្លះទៀតកាន់ដុំថ្ម បាននាំគ្នាគប់ និងយកដំបងវាយមកលើខ្លួនត្រូវចំក្បាលបែកឈាម ចំណែកឈ្មោះ សាយ ត្រូវពួកវាវាយដំបងចំទ្រូងបណ្តាលឱ្យដួល ទើបពួកខ្លួនរត់ចោលម៉ូតូ បានបន្តិចឈ្មោះ សាយ ស្រែកថា ជួយផង ឈឺទ្រូងណាស់ ហើយខ្លួនក៏យកវាទៅមន្ទីរពេទ្យ ប្រហែលជាមួយម៉ោងក្រោយមក វាស្លាប់តែម្តង។

-វត្ថុតាងដែលសមត្ថកិច្ចចាប់យកបាននៅកន្លែងកើតហេតុមាន៖ ១.ដំបងឈើមូលប្រវែង ១៧០សម ទំហំ១៧សម ចំនួន០១, ២.ដំបងឈើមូលប្រវែង ១៤៤សម ទំហំ១១សម ចំនួន០១, ៣.ដំបងឈើមូលប្រវែង៩៦សម ទំហំ១៥សម ចំនួន ០១ ៤.ដំបងឈើមូលប្រវែង ៩៨សម ទំហំ១៧សម ចំនួន០១, ៥.ស្បែកជើងផ្ទាត់ពណ៌ស ចំនួន ០១គូរ, ៦.ស្បែកជើងផ្ទាត់កាម៉ូ ពណ៌ឈាមជ្រូកចំនួន ០១ និង៧.ស្បែកជើងស៊ីកស្មោ ពណ៌ខ្មៅ ០១ចំហៀង។

-ជនជាប់ចោទឈ្មោះ [redacted] ទាំង បានរត់គេចបាត់ និងគេចវេសមិនព្រមចូលផ្តល់ចម្លើយតាមការកោះហៅរបស់តុលាការទេ ដែលបញ្ជាក់ឱ្យឃើញថា ជននេះបានទទួលស្គាល់នូវសកម្មភាពនៃបទល្មើសឃាតកម្មគិតទុកជាមុនរបស់ខ្លួនយ៉ាងពិតប្រាកដ។

៣-ចំពោះវត្ថុតាងមាន ១.ដំបងឈើមូលប្រវែង ១៧០សម ទំហំ១៧សម ចំនួន០១, ២.ដំបងឈើមូលប្រវែង ១៤៤សម ទំហំ១១សម ចំនួន០១, ៣.ដំបងឈើមូលប្រវែង៩៦សម ទំហំ១៥សម ចំនួន០១ ៤.ដំបងឈើមូលប្រវែង ៩៨សម ទំហំ១៧សម ចំនួន០១, ៥.ស្បែកជើងផ្ទាត់ពណ៌ស ចំនួន ០១គូរ, ៦.ស្បែកជើងផ្ទាត់កាម៉ូ ពណ៌ឈាមជ្រូក ចំនួន ០១ និង៧.ស្បែកជើងស៊ីកស្មោ ពណ៌ខ្មៅ ០១ចំហៀង ជាមធ្យោបាយប្រព្រឹត្តបទល្មើសឃាតកម្មគិតទុកជាមុនរបស់ជនជាប់ចោទ គប្បីតុលាការរឹបអូសបំផ្លាញចោល។

៤-តំណាងអយ្យការប្តឹងសុំឱ្យតុលាការសម្រេចផ្តន្ទាទោស ១.ឈ្មោះ [redacted] ខែសា ហៅ សាល ភេទប្រុស អាយុ ១៧ឆ្នាំ ជាតិខ្មែរ, ២.ឈ្មោះ [redacted] ផានី ភេទប្រុស អាយុ ១៨ឆ្នាំ និង ៣.ឈ្មោះ [redacted] ទាង ភេទប្រុស អាយុ ២០ឆ្នាំ ពីបទ៖ "ឃាតកម្មគិតទុកជាមុន" ប្រព្រឹត្តនៅភូមិក្រយាត្បូង ឃុំក្រយា ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ កាលពីថ្ងៃទី២៤ ខែធ្នូ ឆ្នាំ ២០១៧ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា គប្បីតុលាការពិចារណា និងសម្រេចតាមការប្តឹងសុំ។

៥- មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានថា៖ កូនក្តីរបស់ខ្លួនបានទទួលស្គាល់កំហុសហើយ ហេតុនេះ សូមតុលាការសម្រេចបន្ធូរបន្ថយទោសឱ្យកូនក្តីរបស់ខ្លួនផង គប្បីតុលាការពិចារណា។



CamScanner

៦-ជនជាប់ចោទឈ្មោះ [redacted] ខៃសា ហៅ សាល និងឈ្មោះ [redacted] ផានី សំណូមពរឱ្យតុលាការបន្ធូរបន្ថយទោសឱ្យខ្លួន គប្បីតុលាការពិចារណា។

៧-ទង្វើរបស់ជនជាប់ចោទ ១.ឈ្មោះ [redacted] ខៃសា ហៅ សាល ២.ឈ្មោះ [redacted] ផានី និង ៣.ឈ្មោះ [redacted] ទាង ជាបទ៖ "ឃាតកម្មគិតទុកជាមុន" បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលបញ្ញត្តិឱ្យផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត។

៨- ជនជាប់ចោទឈ្មោះ [redacted] ខៃសា និងឈ្មោះ [redacted] ផានី មិនធ្លាប់ប្រព្រឹត្តបទល្មើសពីមុនមកទេ និងបានសហការជាមួយតុលាការក្នុងការផ្តល់ចម្លើយអំពីអង្គហេតុនៃបទល្មើសឃាតកម្មគិតទុកជាមុន គប្បីតុលាការសម្រេចផ្តល់នូវស្ថានសម្រាលទោសដល់ជនជាប់ចោទតាមបញ្ញត្តិមាត្រ៩៥ នៃក្រមព្រហ្មទណ្ឌ ដែលបញ្ញត្តិថា កាលណាបទល្មើសត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ចៅក្រមដែលផ្តល់នូវស្ថានសម្រាល អាចប្រកាសទោសដាក់ពន្ធនាគារក្នុងចន្លោះរវាង ១៥(ដប់ប្រាំ)ឆ្នាំ និង ៣០(សាមសិប)ឆ្នាំ ។

៩-មានភស្តុតាងដាក់បន្ទុក និងមានធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ ដែលបង្ហាញពីពិរុទ្ធភាពរបស់ជនជាប់ចោទដែលអាចឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទឈ្មោះ ១.ឈ្មោះ [redacted] ខៃសា ហៅ សាល ២.ឈ្មោះ [redacted] ផានី និង ៣.ឈ្មោះ [redacted] ាង ពីបទ៖ "ឃាតកម្មគិតទុកជាមុន" ប្រព្រឹត្តនៅភូមិក្រយាត្បូង ឃុំក្រយា ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ កាលពីថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

១០-ជនជាប់ចោទជានីតិជន និងមិនមានភស្តុតាង ឬសញ្ញាណណាដែលបញ្ជាក់ថា ជនទាំងនេះមានវិបល្លាសស្មារតីទេ ហេតុដូច្នេះជនជាប់ចោទត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើរបស់ខ្លួន។ អំពើរបស់ជនជាប់ចោទធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយសង្គម។

១១-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] លេម ទាមទារសំណងជម្ងឺចិត្តចំនួន ១៥.០០០(មួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក គប្បីតុលាការពិចារណា និងសម្រេចលើសំណងរដ្ឋប្បវេណីតាមស្ថានភាពនៃបទល្មើស។

១២-ដើម្បីអនុវត្តទោសដាក់ពន្ធនាគារលើជនជាប់ចោទឈ្មោះ [redacted] ទាង តាមអំណាចសាលក្រមនេះ គប្បីតុលាការបង្គាប់ឱ្យចាប់ខ្លួនឈ្មោះ [redacted] ទាង មកអនុវត្តទោសក្នុងពន្ធនាគារខេត្តកំពង់ធំ។

## ហេតុដូច្នេះ សាលាដំបូងខេត្តកំពង់ធំ
## វិនិច្ឆ័យសេចក្តី

**១-ផ្តន្ទាទោសជនជាប់ចោទ៖**

១-ឈ្មោះ [redacted] **ខៃសា ហៅ សាល** ភេទប្រុស អាយុ ១៧ឆ្នាំ ជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ)

២-ឈ្មោះ [redacted] **ផានី** ភេទប្រុស អាយុ ១៨ឆ្នាំ ជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ)

៣-ឈ្មោះ [redacted] **ទាង** ភេទប្រុស អាយុ ២០ឆ្នាំ (មានសាវតាជាតិដូចខាងលើ)៖ ដាក់ពន្ធនាគារក្នុងម្នាក់ៗ កំណត់រយៈពេល **១៥(ដប់ប្រាំ)ឆ្នាំ** ពីបទ៖ **"ឃាតកម្មគិតទុកជាមុន"** ប្រព្រឹត្តនៅភូមិក្រយាត្បូង ឃុំ

ក្រយា ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ កាលពីថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៧ តាមបញ្ញត្តិមាត្រា២០០ និងមាត្រា ៩៥ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

២-បង្គាប់ឱ្យចាប់ខ្លួនជនជាប់ចោទឈ្មោះ [redacted]ឆាង ភេទប្រុស អាយុ ២០ឆ្នាំ ជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) យកមកអនុវត្តទោសដាក់ពន្ធនាគារក្នុងពន្ធនាគារខេត្តកំពង់ធំ តាមបញ្ញត្តិមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៣-បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] ខៃសា ហៅសាល, ឈ្មោះ [redacted]ផានី និងឈ្មោះ[redacted]ឆាង រួមគ្នាសងសំណងរដ្ឋប្បវេណីឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] លេម ចំនួន ២០.០០០.០០០(ម្ភៃលាន)រៀល ទាមទារលើសពីនេះ បដិសេធចោល ។

៤-វត្ថុតាងមាន៖ ១.ដំបងឈើមូលប្រវែង១៧០សម ទំហំ១៧សម ចំនួន០១, ២.ដំបងឈើមូលប្រវែង ១៤៤សម ទំហំ១១សម ចំនួន០១, ៣.ដំបងឈើមូលប្រវែង៩៦សម ទំហំ១៥សម ចំនួន០១ ៤.ដំបងឈើមូលប្រវែង៩៨សម ទំហំ១៧សម ចំនួន០១, ៥.ស្បែកជើងផ្ទាត់ពណ៌ស ចំនួន ០១គូរ, ៦.ស្បែកជើងផ្ទាត់កាម្ចី ពណ៌ឈាមជ្រូក ចំនួន០១ និង៧.ស្បែកជើងស៊កស្នោ ពណ៌ខ្មៅ ០១ចំហៀង រឹបអូសបំផ្លាញចោល ។

៥-សាលក្រមនេះ បានបញ្ចប់ការជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ខៃសា ហៅ សាល និងឈ្មោះ [redacted] ផានី និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted]ឆាង និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]លេម ។

*-ទុកសិទ្ធិឱ្យភាគីអវត្តមានប្តឹងទាស់ និងទុកសិទ្ធិឱ្យគូភាគីប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។*

**ចៅក្រមប្រឹក្សាជំនុំជម្រះ** — [redacted]

**ចៅក្រមប្រឹក្សាជំនុំជម្រះ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** — [redacted]

**ក្រឡាបញ្ជីសវនាការ** — [redacted]